# Stop N' Shop Discount Liquor

2305 Admiral Wilson Blvd., Camden, NJ 08105 ,Phone: ( 856 ) 365-4377 Fax: ( 856 ) 365-1342



**REMY MARTIN**
V.S.O.P. $35.99 750 ML.
X.O. $99.99 750 ML.




**HENESSY V.O.S.P.**
$39.99
750 ML.




**MARTELL CORDON BLUE**
$93.99
750 ML.



**COURVOISIER XO**
$99.99
750 ML.




**ABSOLUT VOLKA**
$18.09 750 ML.
$29.09 1.75 L.

***Store Hours :***
***Mon. -Thurs.***
***9am – 10pm***
***Fri – Sat. 9am – Midnight***
***Sunday Noon – 10p.m***

***OPEN 365 DAYS***











BEER :
Tsing Tao........12 Oz. 24 Loose Btls. $23.99
Heineken ........12 Oz. 24 Loose Btls. $23.99
Corona...........24 Loose Btls. $23.99
"33" Export Vietnam......................$29.99
Bud................12 Oz. Loose Btls. $15.99
Sapporo.........12 Oz. 24 Loose Btls. $24.99

# លទ្ធផលនៅការបោះឆ្នោត២០១០នៅរដ្ឋផែនស៊ីវេនា
# Pennsylvania 2010 Election Results

*By Sabane Thach*

Novemeber 2nd was a tight race for America. Republication took control of the US House of Representative with 239 seats comparing to 183 seats for Democrat. However, the Democrat still remains majority in the U.S. Senate seats with 51 seats comparing to 46 seats for Republicans.



In Pennsylvania, celebration goes big for republican. Despite the President Barack Obama visited Pennsylvania three times in October to inspire voters to support Joe Sestak, plus the first lady one trip to empower voter participation at University of Pennsyl- vania on November 1st, the U.S. Senate Republican candidate Pat Toomey turned out 51% leaving Joe Sestak 49%.



PA Governor Candidates—The republican candidate Tom Corbett also won the election, he landed 55% comparing to 45% for Dan Onorator from Democrat party.



In Pennsylvania, the democrat also lost U.S. House of Representatives to republican. From District 7, Pat Meehan (R) came out 55%, Bryan Lentz (D) 44%



To District 8, Mike Fitzpatrick (R) turned out 54% and Patrick Muphy (D) 47%




YOO'S AUTO SERVICE AND BODY

អបអរសាទរខួបឆ្នាំទី២០
នៃផ្នែកជួសជុលរថយន្ត និងខួបទី១នៃផ្នែកគ្រឿងបន្លាស់



សេវាជួសជុល យូ អរគុណដល់អតិថិជន
ដែលបានគាំទ្រយើងតាំងពី២០ឆ្នាំមក

ពីព្រោះតែមានការគាំទ្រចំនួន២០ឆ្នាំមកហើយនោះ យើងខ្ញុំ និង
សងគុណដោយបញ្ចុះថ្លៃជូនអតិថិជនទាំងអស់វិញ នាខួប២០ឆ្នាំ
របស់សេវាជួសជុលរថយន្ត យូ ។
សូមពិនិត្យមើលតារាងខាងស្តាំ

| | | |
|---|---|---|
| Combo 1 | Oil Change and Filter<br>Free Tire Rotation<br>(Regular 5W-30 Oil Only UP TO 5Q) | $19.95 +Tax |
| Combo 2 | State Safty Inspection<br>State Emissions Inspection | $39.95 +Tax |
| Combo 3 | Oil Change and Filter<br>Tire Rotation<br>State Safty Inspection<br>State Emissions Inspection | $55.95 +Tax |

Combo 1, 2 and 3 Includes Free Visual Inspection

Belts, Hoses, Airfilter, Transmission Fluid, Engine Oil, Power Steering Fluid, Brakefluid, Antifreeze, Windshield Washer Fluid, Windshield Wiper, Brake Pads, Brake Shoes, Tires, Tire Air Pressure, Shocks, Struts, Front end Check, Exhaust System and More

TEL.(215)457-7777/7779 FAX.(215)457-7475
189W. Duncannon Ave., Phila, PA 19120


ទទួលថតវីឌីអូ និងរូបថតសន្ទឹក
ស្នាត់ជំនាញផ្នែក អាពាហ៍ពិពាហ៍
ខួបកំណើត បុណ្យទាន និង ពិធីផ្សេងៗ
ទទួលកាត់តវីឌីអូ ការាអូខេ
ទទួលប្តូរប្រព័ន្ធ PAL ទៅ NTSC
ទទួលថតសំរាប់ផ្សាយពាណិជ្ជកម្ម
មានបទពិសោធន៍ជាង ២០ឆ្នាំ
ធានាគុណភាពល្អបំផុត
បានលទ្ធផលយ៉ាងឆាប់រហ័ស
CLICKS STUDIO
Video & Photography
267-506-8639
សូមទាក់ទង:
ពិសិដ្ឋ 410-940-9338
សុភាព 267-767-2655
សួន 267-253-9302
ចំរើន 267-632-4768
Kavei Band
កាវីតន្ត្រី

# កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយប្រធានសមាគមអតីតយុទ្ធជនខ្មែរ



ដោយ : អ៊ុម លឿម

•••ក្នុងឱកាសលោកប្រធានាធិបតីអាមេរិក បារ៉ាក់ អូបាម៉ា អញ្ជើញមកបំពេញទស្សនកិច្ចការងារនាទីក្រុងហ្វីឡា-ដែលហ្វៀ នាពេលថ្មីៗ កន្លងមកនេះ "ខ្មែរប៉ុស្តិ៍" ក៏ត្រូវបានផ្តល់កិត្តិយសទៅយកព័ត៌មានក្នុងជំនួបដ៏កម្រនោះដែរ តាមរយៈការអញ្ជើញពីសំណាក់ "សមាគមអតីតយុទ្ធជនខ្មែរ" ដែលប្រធានសមាគមនេះបានអះអាងថា ត្រូវបានអញ្ជើញពិសេសពីសេតវិមាន (White House) ដើម្បីឱ្យរដ្ឋាភិបាលសហរដ្ឋអាមេរិកទទួលស្គាល់ជាផ្លូវការ ។

ប៉ុន្តែជាអកុសលបំណងនៃការជួបប្រធានាធិបតីដ៏មានឥទ្ធិពលនេះត្រូវបានខកខានបណ្តាលមកពីការយឺតយ៉ាវក្នុងការធ្វើដំណើរ ។

ឆ្លៀតពេលនេះ "ខ្មែរប៉ុស្តិ៍" ក៏ត្រូវបានសម្ភាសន៍ជាមួយលោក សរិទ្ធ ប៉ែន ជាឧត្តមសេនីយទោ ស្តីពីដំណើររឿងនានាជុំវិញសមាគមអតីតយុទ្ធជនខ្មែររបស់លោក :

អ៊ុម លឿម : ថ្ងៃនេះជាថ្ងៃពិសេសមួយ គឺថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១០ ហើយជាថ្ងៃដែលលោក អូបាម៉ា អញ្ជើញមកកាន់ទីក្រុងហ្វីឡាដែលហ្វៀយើងនេះ តើខាងសមាគមអតីតយុទ្ធជនខ្មែររបស់លោក ទៅជួបលោក អូបាម៉ា គឺមានបំណងផ្តោតសំខាន់ទៅលើអ្វីបាទ? ។

សរិទ្ធ ប៉ែន : បាទគឺគោលបំណងរបស់សមាគមអតីតយុទ្ធជនខ្មែរ ទៅជួបលោក បារ៉ាក់ អូបាម៉ា នេះ គឺចង់ឱ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក បានទទួលស្គាល់ នឹងដឹងឮថា សមាគមអតីតយុទ្ធជនខ្មែរយើងនេះកើតឡើងពីខែ៥ ថ្ងៃទី២ ឆ្នាំ២០១០ ហើយរហូតមកដល់ឥឡូវនេះ មានអាយុនៅក្មេងខ្ចី ។ ដូច្នេះហើយ យើងចង់រៀបចំឱ្យក្មេងជំនាន់ក្រោយឱ្យធ្វើកិច្ចការសម្រាប់ជួយអតីតយុទ្ធជនខ្មែរ ដែលពួកគាត់មានអាយុចាស់ជរាណាស់ទៅហើយ ។ ហើយយើងមានគោលបំណងចង់មានជាមជ្ឈមណ្ឌលវប្បធម៌សម្រាប់កូនខ្មែរជំនាន់ក្រោយ ។

អ៊ុម លឿម : ដូច្នេះ តើលោកអាចនិយាយបានទេ ពីភាពខុសគ្នារវាងក្រុមអតីតយុទ្ធជនដែលដឹកនាំដោយលោក ថាច់ ម៉ារិន ហើយរូបលោកផ្ទាល់ក៏ជាអតីតនៃសមាជិកម្នាក់នៅក្នុងក្រុមនោះដែរ ។

សរិទ្ធ ប៉ែន : ខ្ញុំចង់បកស្រាយរឿងហ្នឹងដែរ កាលពីដើមឡើយខ្ញុំជាអតីតយុទ្ធជនរបស់ US-JSC ជាអក្សរកាត់ ហើយដែលមានអក្សរពេញជា United States Volunteers-Joint Services Command ។ ហើយក្រុមពីមុននោះ ជាក្រុមអតីតយុទ្ធជនចម្រុះ មិនថា ខ្មែរ, លាវ,យួន,ចិនឬកូរ៉េអ្វីទេ ហើយដោយខ្ញុំយល់ឃើញថា ខ្លាចបាត់បង់ Fund របស់ខ្មែរយើងហ្នឹងទើបខ្ញុំបំបែកចេញជាសមាគមអតីតយុទ្ធជនខ្មែរពិតប្រាកដឡើងវិញ ដោយទទួលយកតែខ្មែរសុទ្ធសាធ និងក្មេងជំនាន់ក្រោយជាទំពាំងស្នង ឫស្សី ។

អ៊ុម លឿម : ឥឡូវជាថ្មីម្តងទៀត តើលោកអាចបញ្ជាក់ឱ្យបានច្បាស់ទេថា តើក្រុមរបស់លោកហ្នឹងពិតជាបានទទួលស្គាល់ជាលក្ខណៈផ្លូវច្បាប់ពីរដ្ឋាភិបាលអាមេរិកហើយឬនៅ?

សរិទ្ធ ប៉ែន : រឿងហ្នឹងយើងបានផ្សព្វផ្សាយរួចអស់ហើយ,យើងមានក្រដាស់ស្នាមតាមលក្ខណៈផ្លូវច្បាប់ត្រឹមត្រូវឡើងទៅលើ យើងមានក្រដាសបង់ឱ្យ IRS និងតាក់ត្រឹមត្រូវ ដូច្នេះយើងជឿជាក់ថា សហរដ្ឋអាមេរិកពិតជាទទួលស្គាល់ ។

អ៊ុម លឿម : ចំពោះសមាជិកទាំង២៤រូបនៃក្រុមរបស់លោក ដូចដែលលោកបានជម្រាបពីមុនហ្នឹង តើពួកគាត់ទទួលបានប្រាក់បៀវត្សរ៍ណាមួយទេបាទ?



ឧត្តមសេនីយទោ សរិទ្ធ ប៉ែន

សរិទ្ធ ប៉ែន : ពេលនេះប្រាក់ខែពួកគាត់នៅមិនទាន់មានទេ ប៉ុន្តែតាមអ្វីដែលខ្ញុំបានដឹង បៀវត្សរ៍របស់អតីតយុទ្ធជនក្នុងសហរដ្ឋអាមេរិកចំពោះអ្នកមានសញ្ជាតិជាអាកាំង គឺគេមានបៀវត្សរ៍ត្រឹមត្រូវមានប័ណ្ណសុខភាពត្រឹមត្រូវ ដូច្នេះហើយយើងក៏ចង់ទាមទារដល់ក្រុមខ្មែររបស់យើងឱ្យបានដូចគេដែរ ។

អ៊ុម លឿម : គោលបំណងសំខាន់បំផុតក្នុងការបង្កើតសមាគមអតីតយុទ្ធជនខ្មែរនេះឡើង គឺផ្តោតទៅលើកត្តាសំខាន់អ្វីខ្លះ?

សរិទ្ធ ប៉ែន : សមាគមអតីតយុទ្ធជនខ្មែរយើងនេះមានទិសដៅចំនួន៣ ដោយទី១ គឺជាអង្គការមួយសម្រាប់បំរើផ្នែកមនុស្សធម៌ ។ ទី២ សមាគមនេះគឺចង់ជួយជំរុញក្មេងជំនាន់ក្រោយ ឱ្យមានកិច្ចការងារធ្វើ ឱ្យមានការរៀនសូត្រផ្នែកអក្សរសាស្ត្រ សង្គមសាស្ត្រ ប្រវត្តិសាស្ត្រ និងប្រពៃណីខ្មែរ វប្បធម៌ខ្មែរឱ្យមានភាពល្អតលាស់ ។ ហើយទី៣ គឺយើងចង់រៀបចំជួយដល់អតីតយុទ្ធជនមិនថា នៅក្រៅប្រទេស ឬក្នុងប្រទេសដែលធ្លាប់ឆ្លងកាត់ក្នុងសមរភូមិដែលប្រឆាំងនិងពួកកុម្មុយនិស្តហ្នឹង គឺយើងចង់លើកស្ទួយពួកគាត់ ។

អ៊ុម លឿម : តើក្រុមអតីតយុទ្ធជនពីមុនដែលមានលោក ថាច់ ម៉ារិន ជាអ្នកដឹកនាំ និងក្រុមអតីតយុទ្ធជនដែលដឹកនាំដោយរូបលោកផ្ទាល់ មានការសហការណ៍គ្នា ឬការនៅឃ្លាតឆ្ងាយពីគ្នាយ៉ាងណាដែលបាទ?

សរិទ្ធ ប៉ែន : រឿងនេះឈរនៅលើគោលជំហរអ្នកដឹកនាំ ដែលគោលជំហរខ្ញុំសព្វថ្ងៃ គឺចង់ឱ្យមានការជិតស្និទ្ធគ្នាឡើងវិញ អត់ចង់ឱ្យមានការបែកបាក់ គឺចង់ឱ្យមានការបង្រួបបង្រួមគ្នា ។

អ៊ុម លឿម : ខ្ញុំបាទឃើញនូវពាក្យមួយថា "អតីតយុទ្ធជន" អីចឹងទេ មានន័យថា រាល់សមាជិកទាំងអស់ គឺសុទ្ធសឹងជាអ្នកធ្លាប់ឆ្លងកាត់ជីវិតជាអ្នកកាន់កាំភ្លើងមែនទេ?

(តទៅទំព័រទី ១៩)

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ
Angkor International Travel Agency




World Wide Travel & Tour Service
Cambodia - Vietnam - Laos - Thailand

ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ
សេវាលិខិតឆ្លងដែន
សេវាអន្តោប្រវេសន៍
កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR, CHINA , ASIANA KOREAN AIRLINES,

ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER
904 South 8th Street. Philadelphia, PA 19147
Tel : 215-625-2889; Fax : 215-625-9395
Cell : 267-934-9888; Email : centuryphl@yahoo.com

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន_វៀតណាម

តមកទំព័រទី ០១

# ពិភពលោករំញ្ជួយដោយសារសន្និសីទ...

នៃថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០១០ ជាទិវាប្រវត្តិសាស្ត្រសំរាប់ជាតិខ្មែរទាំងមូល ត្រូវបង្ហាញនូវសាមគ្គីភាព និងបំណងរកសន្តិភាពពិតប្រាកដជាមួយនឹងប្រទេសជិតខាង គឺសៀម និងយួន។

**គោលបំណង**

១- បង្ហាញនូវសាមគ្គីភាពជាតិ មិនឱ្យមានការប្រមាថមាក់ងាយពីប្រទេសជិតខាង ។

២- បង្ហាញឱ្យប្រទេសជិតខាងបញ្ឈប់ជាបន្ទាន់នូវអំពើឈ្លានពានមកលើកម្ពុជា។

៣- ដើម្បីដាក់ញត្តិទាមទារឱ្យលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិជួយដោះស្រាយបញ្ហាវិបត្តិព្រំដែនខ្មែរ ដែលកំពុងកើតមានជម្លោះជាមួយប្រទេសជិតខាង និងរើររើពិនិត្យមើលឡើងវិញនូវការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ២៣ តុលា ១៩៩១ សម្រាប់កម្ពុជា។

**ញត្តិ**

ជូនលោក នីកូឡា សារកូស៊ី (NICOLA SARKOZY) ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង និងជាសហប្រធាននៃសន្និសីទសន្តិភាព នៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា

យើងខ្ញុំជាតំណាងសង្គមស៊ីវិលខ្មែរ និងជនជាតិខ្មែរ ព្រមទាំងញាតិមិត្តរស់នៅក្នុងប្រតេសបារាំង បានរួមប្រជុំគ្នាក្នុងបាតុកម្មនៅទីលានសិទ្ធិមនុស្ស នៃទីក្រុងប៉ារីស នាថ្ងៃទី២៥ តុលា ២០០៩ ដើម្បីរឭកគុណនៃកិច្ចព្រមព្រៀងសន្តិភាពនៃក្រុងប៉ារីស ស្តីពីកម្ពុជា ចុះថ្ងៃទី២៣ តុលា ១៩៩១។

**បានសង្កេតឃើញ :**

១. រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានក្តោបក្តាប់ដោយអំណាចផ្តាច់ការ... ដោយចេតនាលើសិទ្ធិមូលដ្ឋានរបស់មនុស្ស និងរបស់ពលរដ្ឋលើរដ្ឋធម្មនុញ្ញ និងលើគោលការណ៍ប្រជាធិបតេយ្យ។

២. តាំងពីឆ្នាំ១៩៩១មក ការសម្លាប់អ្នកជំទាស់នយោបាយ អ្នកសហជីព អ្នកសារព័ត៌មាន និងអ្នកច្បាប់ឯករាជ្យជាច្រើនរយនាក់...។

៣. ក្នុងបច្ចុប្បន្នកាលនេះ ការចាប់យកដីធ្លីរបស់ប្រជាជននិងការបណ្តេញប្រជាជនចេញពីទឹកដីនិងលំនៅរបស់គេ...។

៤. ក្នុងបច្ចុប្បន្នកាលនេះ ការរំលោភអំណាចបានកើតមានជាអចិន្ត្រៃយ៍ដោយរដ្ឋាភិបាលនេះបណ្តាលឱ្យកងនគរបាល កងយោធា និងបណ្តាញតុលាការ ធ្វើការសង្កត់សង្កិនយ៉ាងឃោរឃៅដោយបំពានច្បាប់ទៅលើរាល់ការទិទាន និងការតវ៉ាដ៏ត្រឹមត្រូវរបស់ពលរដ្ឋ និងអ្នកនយោបាយជំទាស់ ។

៥. ចំណែកពីខាងក្រៅស្រុកវិញ វៀតណាមដែលបានចុះកិច្ចព្រមព្រៀងសន្តិភាពនៃទីក្រុងប៉ារីសនេះដែរ បានបន្តការធ្វើអាណានិគមឥតស្រាកស្រាន្តនៃកម្ពុជាដោយការឃុបឃិតនៃលោក ហ៊ុន សែន និងបក្សរបស់គាត់ តាំងពីឆ្នាំ១៩៧៩មក ហើយឥឡូវនេះគេបានប្រមាណថា ពួកដែលហៅថា "អន្តោប្រវេសន៍" វៀតណាម មានចំនួនជាង៥លាននាក់ គឺជាង៣៥% នៃប្រជាជន១៤លាននាក់នៃកម្ពុជា... ។

៦. ក្នុងពេលជាមួយគ្នានេះ វៀតណាមបានបន្តការជ្រៀតជ្រែកឥតឈប់ឈរក្នុងកិច្ចការនៃរដ្ឋាភិបាលកម្ពុជា តាមរយៈនៃកិច្ចព្រមព្រៀងធ្វើ "សហប្រតិបត្តិការ" ក្នុងគ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ទាំងអស់...។

៧. នៅមុខអំពើរំលោភគ្រប់បែបយ៉ាងនៃវៀតណាមនេះ ប្រទេសថៃ ដែលបានចុះកិច្ចព្រមព្រៀងសន្តិភាពនៃទិណក្រុងប៉ារីស ដូចគ្នាដែរ ក៏បានចូលកាន់កាប់ទឹកដីខ្មែរជាច្រើនកន្លែង រំលោភលើសិទ្ធិរបស់ប្រជាជនខ្មែរ ក្នុងខេត្តខ្មែរខាងលិច និងខាងជើងរួមមានទាំងប្រាសាទព្រះវិហារ...។

យោងតាមសភាពការណ៍ទាំងអស់ខាងលើ យើងខ្ញុំដែលចុះហត្ថលេខាលើសេចក្តីញត្តិនេះ ដោយបានយល់ទៀតថា :



ក្រុមបាតុករនៅ San Fancisco សហរដ្ឋអាមេរិក

បន្ទាប់ពីទទួលការឈឺចាប់ឥតគណនា អំពីសង្គ្រាមរាប់សិបឆ្នាំ អំពីការសម្លាប់រង្គាល និងអំពីការកាន់កាប់ប្រទេសដោយវៀតណាមនោះ ការចុះកិច្ចព្រមព្រៀងសន្តិភាពនៃទីក្រុងប៉ារីស ស្តីពីកម្ពុជានាថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ បានផ្តល់ពីដំបូងភ្លាមនូវសេចក្តីសង្ឃឹមមួយយ៉ាងធំធេងដល់ប្រជាជនខ្មែរទាំងមូលថាគេនឹងមានសិទ្ធិសេរីភាពជាថ្មី និងរស់ក្នុងរបបប្រជាធិបតេយ្យ ហើយប្រទេសកម្ពុជានឹងមានឯករាជ្យមានបូរណភាពទឹកដីពេញលេញវិញ។ ប៉ុន្តែក្នុងភាពជាក់ស្តែងអ្វីៗទាំងអស់បានក្លាយជាធ្ងន់ធ្ងរថែមទៀត ហើយប្រជាជន និងប្រទេសកម្ពុជានៅតែពុំបានស្គាល់សន្តិភាព និងសន្តិសុខ ដែលគេបានគ្រោងទុកនោះ និងត្រូវរស់ជានិច្ចក្នុងភាពតោកយ៉ាក និងក្នុងការភ័យរន្ធត់ចំពោះអំណាចផ្ទៃក្នុង និងចំពោះការជាន់សង្កត់នៃបរទេសជិតខាង ។

យើងខ្ញុំសូមអំពាវនាវ ដោយទទូចបំផុតដល់លោកប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកជាសហប្រធាននៃសន្និសីទសន្តិភាព នៅក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា សូមលោកពិនិត្យនូវលទ្ធភាពនៃការបង្កើត **គណៈកម្មការអន្តរជាតិ ត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពនៃក្រុងប៉ារីស ស្តីពីកម្ពុជា** នេះដោយមានភារៈកិច្ចជំរុញឱ្យរដ្ឋាភិបាលកម្ពុជា វៀតណាម និង ថៃឡង់ គោរពយ៉ាងទៀងទាត់ចំពោះបទបញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀង ដើម្បីជួយប្រទេសកម្ពុជា និងប្រជាជនឱ្យបានចាកផុតអំពីស្ថានភាពប្រកបដោយមហាគ្រោះថ្នាក់នៃការរំលាយកម្ពុជា ហើយស្ថាបនាបាននូវសន្តិភាពពេញលេញ ស្ថេរភាព និងសន្តិភាព ដើម្បីការអភិវឌ្ឍន៍ជាចាំបាច់នៃប្រទេសនេះ។

*ធ្វើនៅក្រុងប៉ារីស ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១០*

**អ្នកតំណាងបាតុករ**

***ស៊ាន ប៉េងសែ*** *គណៈកម្មាធិការព្រំដែនកម្ពុជា*
***ថាច់ វៀន*** *សហព័ន្ធខ្មែរកម្ពុជាក្រោម*
***ប៉េង មុនីសាវ៉ា*** *គណបក្សសមរង្ស៊ី*
***លឹម ប៊ុន ស៊ីដារេត*** *គណបក្សសិទ្ធិមនុស្ស*
***ទី ហៃ ដានី*** *សហព័ន្ធខ្មែរការពារសិទ្ធិមនុស្ស*
***ឡុង គុន្ធី*** *សមាគមវប្បធម៌ខ្មែរ លីយ៉ុង*
***លឹម គឹមយ៉ា*** *កិច្ចការទំនាក់ទំនងជាមួយបាតុករ*

***កំណត់ :*** សេចក្តីញត្តិនេះ ក៏ត្រូវបានផ្ញើរជូនជាមួយគ្នាដល់

លោក ស៊ុស៊ីលោ បមបាង យុធោយោនោ (SUSILO BAMBANG YUDHOYONO) ប្រធានាធិបតីនៃសាធារណរដ្ឋ ឥណ្ឌូនេស៊ី និងជាសហប្រធាននៃសន្និសីទសន្តិភាពនៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជាដែរ ៕

**សេចក្តីប្រកាសនៃគណៈកម្មាធិការព្រំដែនកម្ពុជា**

នាឱកាសខួបទី១៩ នៃកិច្ចព្រមព្រៀងសន្តិភាព នាក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា ថ្លែងដោយលោក ស៊ាន ប៉េងសែ នៅថ្ងៃទី២៤ តុលា ២០១០




***បងប្អូនរួមជាតិ និងមិត្តជាទីគោរព***

យើងមកជួបជុំគ្នា នាថ្ងៃនេះ នៅ"លាននៃសិទ្ធិមនុស្ស" នៃទីក្រុងប៉ារីស ដើម្បីស្រែកប្រាប់សកលលោកនូវសេចក្តីឈឺចាប់ និងកំហឹងរបស់យើងចំពោះពួកអ្នករំលោភកិច្ចព្រមព្រៀងសន្តិភាព នាទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា ជាទីស្រឡាញ់របស់យើង ។ សំរែករបស់យើងនៅទីនេះ ធ្វើឡើងមិនត្រឹមតែក្នុងនាមយើងផ្ទាល់ខ្លួនទេ គឺធ្វើក្នុងនាមអ្នកស្នេហាជាតិ និងប្រជាជនខ្មែរទាំងអស់នៅក្នុងស្រុកដែរ ដែលគ្នាមិនអាចធ្វើបាតុកម្មនេះបាន ។

កិច្ចព្រមព្រៀងក្រុងប៉ារីសនេះ មានគោលដៅច្បាស់ គឺផ្តល់សន្តិភាពឱ្យកម្ពុជា និងសេរីភាពឱ្យប្រជាជនខ្មែរ។ ប៉ុន្តែវៀតណាម និងពួកខ្មែរចូលដៃជាមួយគេ ដែលបានក្បត់សេចក្តីសង្ឃឹមនៃប្រជាជនខ្លួន និងប្រយោជន៍នៃមាតុភូមិរបស់ខ្លួន បានសំរេចចិត្តបន្តនយោបាយគ្របសង្កត់ និងធ្វើសម្ពាធគ្រប់យ៉ាងមកលើស្រុកយើង និងប្រឆាំងនឹងប្រជាជនយើងជានិច្ច ។

កិច្ចព្រមព្រៀងក្រុងប៉ារីស បានដាក់កំហិតឱ្យអ្នកបានចុះហត្ថលេខាទាំងអស់គ្នា "ប្រកាន់ ថែរក្សា




ក្រុមបាតុករ Ottawa កាណាដា

និងការពារឯករាជ្យ អធិបតេយ្យ បូរណភាពដែនដីភាពមិនអាចរំលោភបានលើដែនដីកម្ពុជា អព្យាក្រឹតភាព និងឯកភាពនៃជាតិខ្មែរ ។ ប៉ុន្តែវៀតណាមនៅតែបន្តនយោបាយវាតទីរបស់វា ដោយនៅតែបន្តការកាន់កាប់ទឹកដី សមុទ្រ និងកោះខ្មែរ ព្រមទាំងបញ្ជូនបញ្ចូលពួកយួនអាណានិគមបន្ថែមទៀត ហើយឱ្យខ្មែរទទួល "សហប្រតិបត្តិការ" របស់វា ទាំងក្នុងនិស្ស័យប៉ូលីស សន្តិសុខ យោធា ការពារជាតិ រដ្ឋបាលច្បាប់-តុលាការទាំងអស់ជាមួយ ហ៊ុន សែន និង "បក្សប្រជាជនកម្ពុជា"របស់គាត់ ៕

DRANOFF ASSOCIATES
*Attorneys at Law*

"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។



ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យលោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្ប៉ាញ៉ុល ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

- របួសលើរាងកាយ : គ្រោះថ្នាក់រថយន្ត, ឡានឈ្នួល "សិបតា", ឡានត្រឹក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬកំឆ្កែខាំ... ។
- ការប្រហែសក្នុងវិជ្ជាជីវៈ និងសិទ្ធិរបស់អតិថិជន : ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, វាយមាយក្នុងការថែទាំមនុស្ស... ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

## តមកទំព័រទី ០៧ រំឭកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣...

ដោយតែមេដឹកនាំកាល ពីក្រោយថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣នេះហើយ ពុំមានសមត្ថភាពគ្រប់គ្រាន់ ដូច្នេះគឺថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នេះហើយជាថ្ងៃ ធ្វើឱ្យប្រទេសកម្ពុជាមានសន្តិភាព រីកចំរើនលូតលាស់គ្រប់វិស័យ និងមានមេដឹកនាំមានប្រាជ្ញាឈ្លាសវៃឆ្លាត មានឧត្តមគតិ ហើយនិងគតិយុត្តិធម៌ល្អជាងមេដឹកនាំខ្មែរពីសម័យមុនៗទាំងអស់។

ទោះបីជាមានជនជាតិខ្មែរជាច្រើន មានទស្សនៈយល់ឃើញថា ការថ្លែងប្រកាសរបស់មេដឹកនាំខ្មែរនេះ គឺជាគំនិតផ្ទាល់ខ្លួនតែម្នាក់ឯងប៉ុណ្ណោះ តាមការពិតដែលជាតិខ្មែរបានឃើញនោះ វាពុំមានអ្វីបង្ហាញពីឯករាជ្យភាពពិតប្រាកដនៅក្នុងមាតុភូមិខ្មែរទាល់តែសោះ កាលបើប្រៀបធៀបទៅនឹងប្រទេសនានា ដូចជាប្រទេសចិន ប្រទេសជប៉ុន ប្រទេសកូរ៉េ និងប្រទេសយួនជាដើម គ្មានវិស័យណាមួយ ដែលគេមើលឃើញថា ប្រទេសខ្មែរជាប្រទេសមានឯករាជ្យពេញបរិបូរនោះ ដូចជា សេដ្ឋកិច្ចជាតិ កងទ័ពជាតិ សិក្សាធិការអប់រំជាតិ រដ្ឋបាលជាតិ ជាពិសេសវិស័យជនអន្តោប្រវេសន៍ខុសច្បាប់ជាតិយួន បានចូលមករស់នៅក្នុងស្រុកខ្មែរជាច្រើនលាននាក់ដោយសេរីពេញច្បាប់ ព្រមទាំងបញ្ហាព្រំដែនដែលជនជាតិខ្មែរមើលឃើញថា ជនជាតិយួន និងសៀម បានរំលោភបំពានយកបានជាស្រេចតាមតែអំពើចិត្ត។

បើសិនណាជាប្រទេសណាមួយត្រូវបានប្រទេសដទៃណាមួយលើកទ័ពចូលឈ្លានពាន ហើយត្រួតត្រា រួចហើយតែងតាំងក្រុមមេដឹកនាំមួយឱ្យដឹកនាំជំនួស ក្រោមការបង្គាប់បញ្ជានៃកងទ័ព និងអ្នកជំនាញការ ទីប្រឹក្សាប្រទេសនោះ ដូច្នេះពុំអាចចាត់ទុកក្រុមមេដឹកនាំប្រទេសនោះ ជាឯករាជ្យពេញបរិបូរទៅបានទេ។ ម្ល៉ោះហើយក្រុមមេដឹកនាំតែងតាំងនេះ ត្រូវតែប្រើប្រាស់គ្រប់វិធានការដើម្បីតម្រូវចិត្តចៅហ្វាយនាយឱ្យតែខ្លួនឯងបានកាន់អំណាចជារៀងរហូតអស់មួយជីវិត។ ទោះបីជាការដឹកនាំនោះប្រកបដោយអគតិ អយុត្តិធម៌ ប៉ះពាល់ដល់អាយុជីវិតប្រជាជាតិ និងប្រទេសយ៉ាងណាក៏ដោយ ក៏មេដឹកនាំតែងតាំងនោះ ពុំអាចឈរនៅក្នុងជួរជាមួយជនជាតិរបស់ខ្លួនបានឡើយ ។

ដោយហេតុនេះហើយ បានជាក្រុមមេដឹកនាំនេះ ប្រព្រឹត្តធ្វើតែអំពើទុច្ចរិត ពុករលួយ ចាប់ចង រហូតសម្លាប់ចោលនូវជនជាតិរបស់ខ្លួនឯង ដោយគ្មានការអាណិតអាសូរទាល់តែសោះ ។

ចំណែកជនជាតិអន្តោប្រវេសន៍ខុសច្បាប់ គេនាំបញ្ចូលមកឱ្យរស់នៅយ៉ាងស្រួលសប្បាយរីករាយឱ្យស្របទៅតាមច្បាប់ទាំងអស់។

**សេចក្តីសន្និដ្ឋាន :**

ឯករាជ្យពេញបរិបូររបស់ប្រទេសកម្ពុជា នាសព្វថ្ងៃនេះ ពុំអាចចាត់ទុកថា ជាឯករាជ្យពិតប្រាកដបានទេ មានន័យថា ប្រទេសកម្ពុជាត្រូវបាត់បង់នូវឯករាជ្យអស់ទៅហើយ ដូចគ្នាប្រទេសខ្មែរកាលពីនៅក្រោមអំណាចអាណានិគមបារាំងកាលពី៥៣ឆ្នាំមុននោះទៅវិញទេ ពីព្រោះប្រទេស និងជនជាតិខ្មែរ សព្វថ្ងៃដែលកំពុងរស់នៅក្រោមអំណាចអាណានិគម និយមថ្មីយួនវៀតណាមសង្គមនិយម ដែលបានប្រើកលល្បិចរសបច្បាប់មួយ អាចបន្លំក្លែងក្លាយខ្លួនឱ្យ ដូចជាជនជាតិខ្មែរបេះបិទ និងប្រើវិធីចិត្តសាស្ត្រដ៏ល្អប្រពៃបោកបញ្ឆោតមតិជាតិខ្មែរ និងអន្តរជាតិឱ្យមើលឃើញ និងយល់ដឹងថា មេដឹកនាំខ្មែរ ដែលតែងតាំងដោយយួនហាណូយនេះ គឺពិតជាជាតិសាសន៍ខ្មែរ ហើយកំពុងតែគ្រប់គ្រងត្រួតត្រា ដឹកនាំប្រទេស និងជនជាតិខ្លួនឯងជាពិតប្រាកដទៅវិញ ដូចសុភាសិតខ្មែរបានពោលថា :

**"ឃើញដំរីស្លាប់ នាំគ្នាយកចង្អេរទៅក្រម" ។**

## សិទ្ធិមនុស្ស

១- សិទ្ធិមនុស្សពិតនៅក្នុងលោក មនុស្សតែងស្វែងរកចង់បានណាស់
សិទ្ធិមនុស្សនេះជួយបំផ្លាស់ ឱ្យមនុស្សស្គាល់ច្បាស់ភាពរុងរឿង ។
២- សិទ្ធិមនុស្សល្អថ្លៃឧត្តម មនុស្សតែងខិតខំដោយព្រមព្រៀង
សិទ្ធិមនុស្សជួយលើកតំកើង ឱ្យមនុស្សបានថ្កើងហើយថ្លៃថ្នូ ។
៣- សិទ្ធិមនុស្សកើត ព្រោះដោយសារ មនុស្សតាំងប្រាជ្ញាខំតស៊ូ
សិទ្ធិមានដោយត្រូវប្តូរ មនុស្សទ្រាំមិនថយទើបបានជ័យ ។
៤- សិទ្ធិមនុស្សខ្លះត្រូវបំបិទ ពីមនុស្សមានចិត្តកាចព្រៃផ្សៃ
សិទ្ធិមនុស្សនេះស្ថិតក្នុងដៃ មេកាចអប្រិយ៍គ្មានសីលធម៌ ។
៥- សិទ្ធិមនុស្សត្រូវជនទៀតត្រង់ ឆន្ទៈអាចអង់មាំមួនល្អ
សិទ្ធិមនុស្សថ្លៃថ្លាបវរ នាំគ្នាក្រោកឈរហើយទាមទារ ។
៦- សិទ្ធិមនុស្សជាសភាពពិត មនុស្សរតូវមានសិទ្ធិគ្រប់ៗគ្នា
សិទ្ធិមនុស្សនេះដែលប្រជា ពលរដ្ឋត្រូវការជួយជីវិត ។
៧- សិទ្ធិមនុស្សថ្កើងព្រោះមេនាំ មេមានឧត្តមមេត្រីចិត្ត
សិទ្ធិមនុស្សច្បាស់ត្រូវតែស្ថិត ក្នុងដៃពិសិដ្ឋខ្មែរទាំងអស់ ។
៨- សិទ្ធិមនុស្សមានភាពរឹងមាំ ជាភាពឧត្តមល្អឥតខ្ចោះ
សិទ្ធិមនុស្សពិតជារបស់ ពលរដ្ឋស្ម័គ្រស្មោះទាំងប្រទេស ។
៩- សិទ្ធិមនុស្សជាអំណាចធំ ជាផ្លូវដឹកនាំផុតជាន់ជិះ
សិទ្ធិមនុស្សខ្លាំងហើយពិសេស នាំខ្មែរឱ្យចេះមានប្រាជ្ញា ។
១០-សិទ្ធិមនុស្សមានប្រៀបដូចអាវុធ ខ្លាំងក្លាបំផុតជួយប្រជា
សិទ្ធិមនុស្សឈ្នះជនឫស្យា ជាមេផ្តាច់ការត្រូវរលាយ ។
១១-សិទ្ធិមនុស្សមានពិតថ្លៃថ្លា នាំជាតិរដ្ឋាបានពណ្ណរាយ
សិទ្ធិមនុស្សពិតភ្លឺព្រោងព្រាយ នាំខ្មែរគ្រប់កាយសប្បាយអើយ ៕

*ក្រុងហ្វីឡា USA ថ្ងៃទី២៧ តុលា ២០១០*

**ម៉ម យ៉ឺន**


# ចូរធ្វើចលនា!



មួយភាគបីនៃក្មេងៗ ប្រឈមមុខចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរខ្លាំងណាស់ ដោយព្រោះតែធាត់ពេក ។ យើងអាចជួយកូនរបស់អ្នកឲ្យជ្រើសរើស ជាមួយនឹង :

- ការចូលជាសមាជិកនៅមណ្ឌលហាត់ប្រាណ
- អត្ថប្រយោជន៍ Weight Watchers® របស់យើង (សំរាប់ក្មេងៗ អាយុ 10+)
- ការប្រឹក្សាខាងអាហារមានជីវជាតិ

CHIP បាននាំមកជូនអ្នកដោយ KidzPartners មានផ្តល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេង ជំទង់ៗ ដែលគ្មានការធានារ៉ាប់រង ។ ថែមទាំងអត្ថប្រយោជន៍ដែល អាចនាំឲ្យមានសុខភាពល្អអស់មួយជីវិត ។

**ចូរដាក់ពាក្យសុំនៅថ្ងៃនេះ!**

**1-888-888-1211**

TTY 1-877-454-8477

Pennsylvania's Children's Health Insurance Program
យើងរ៉ាប់រងក្មេងៗទាំងអស់។

KidzPARTNERS
គំរោងសំរាប់ក្មេងៗរបស់ HEALTH PARTNERS

www.chipcoverspakids.com www.kidzpartners.com

# ស្ត្រីខ្មែរជំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោក



(តពីលេខមុន)

ដោយ : ពិន នារីពិទូ

...ទឹកដីដ៏ធំធេងរបស់ប្រទេស ចិន ជាប់ចំណាត់ថ្នាក់ទីបួននៅលើពិភពលោកបន្ទាប់ពីប្រទេសរុស្ស៊ី កាណាដា និងសហរដ្ឋអាមេរិក និងមានប្រជាជនច្រើនជាងគេលំដាប់ពិភពលោកក្នុងអំឡុងពេល៣០ឆ្នាំនេះ បន្ទាប់ពីបានប្រែក្លាយរចនាសម្ព័ន្ធរបស់ខ្លួនពីទីផ្សារផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរីដែលបានស្រូបយកអ្នកវិនិយោគទុនបរទេសជាច្រើនធ្វើឱ្យប្រទេសនេះមានសន្ទុះសេដ្ឋកិច្ចខ្លាំងក្លានៅអាស៊ីភាគអាគ្នេយ៍ ប៉ុន្តែចំណូលធៀបនឹងមូលធននៅមានកំរិតទាបនៅឡើយ ក្នុងឆ្នាំ២០០៩ ប្រទេសនេះបានក្លាយជាមហាអំណាចសេដ្ឋកិច្ចធំទីពីររបស់ពិភពលោកបន្ទាប់ពីសហរដ្ឋអាមេរិក។ អ្នកធ្វើដំណើរផ្សងព្រេងទាំងពីរ គឺអ្នកអង្គម្ចាស់ ស៊ីលវីយ៉ា និង អូរ៉េលី (Sylvia និង Aurélie) បានចំណាយពេលអស់មួយថ្ងៃឆ្លងកាត់ខេត្ត Datong គយគន់ទេសភាពព្រមទាំងរបៀបរស់នៅនៃប្រជាជននៅទីនោះដែលកំពុងប្រកបរបរធ្វើចំការ។ ថ្ងៃស្អែកក៏បានចេញដំណើរឆ្ពោះទៅទីក្រុងប៉េកាំង Beijing ដែលជារាជធានីរបស់ប្រទេសចិន និងជាទីក្រុងប្រវត្តិសាស្ត្រដ៏ល្បីល្បាញជាយូរលង់មកហើយតាំងពីសម័យមុន នៅពេលដែលអ្នកទេសចរណ៍បានឈានជើងចូលក្នុងទឹកដីនៃប្រទេសចិន ម្នាក់ៗសង្ឃឹមថានឹងបានឃើញផ្ទាល់ភ្នែកនូវកេរ្តិ៍ដំណែលវប្បធម៌ដែលបានបន្សល់ទុកតាំងពីសម័យបុរាណរហូតមកទល់បច្ចុប្បន្ននេះ គឺការទស្សនា GreatWall បានទាក់ទាញចំណាប់អារម្មណ៍អ្នកទេសចរណ៍គ្រប់គ្នាឱ្យចូលទស្សនាទីក្រុងនេះរាប់ពាន់នាក់ក្នុងមួយឆ្នាំៗ។ អ្នកអង្គម្ចាស់ ស៊ីលវីយ៉ា និង អូរ៉េលី (Sylvia និង Aurélie) បានឆ្លងកាត់ទីក្រុងប៉េកាំង Beijing ដែលរំពឹងថានឹងបានទៅទស្សនា GreatWall ដែរ ដោយបើកបរនៅតាមផ្លូវជាតិពោរពេញទៅដោយចរាចរណ៍កកស្ទះ។ ក្រោមភ្លៀងរលឹមតិចៗអ្នកទាំងពីរបានដើរនៅលើផ្លូវតូចក្បែរព្រះបរមរាជវាំងដ៏ធំស្កឹមស្កៃ និងដើរមើលការតាំងលក់របស់របរសិប្បកម្មក្រោមពន្លឺភ្លើងតាមបែបបុរាណចិន បន្ទាប់មកបានបោះជំហ៊ានមកដល់តូបលក់អាហារយ៉ាងសាមញ្ញដែលដាក់លក់យ៉ាងច្រើនស្អេកស្កះនៅតាមផ្លូវព្រមទាំងបានភ្លក់នូវរសជាតិអាហារយ៉ាងឈ្ងុយឆ្ងាញ់ និងមានតំលៃថោកសមរម្យ។ ក្រោយមកបានឈប់នៅហាងតែមួយកន្លែង ដើម្បីសំរាលភាពហត់នឿយក្នុងការដើរអស់ពេញមួយថ្ងៃ ព្រមទាំងទស្សនាការនូវសម្តែងរបាំប្រពៃណីចិន គួរជាទីចាប់អារម្មណ៍។ បន្ទាប់ពីដើរលំហែរកាយរួចមកពួកគេបានត្រឡប់ទៅ Beijing វិញដើម្បីទៅទស្សនា GreatWall ដោយធ្វើដំណើរតាមរថយន្តក្រុង ហើយបន្តដំណើរដោយថ្មើរជើងមកដល់គោលដៅ នៅពេលយប់ពួកគេក៏បានបញ្ឈប់ដំណើរនៅក្នុងភោជនីយដ្ឋានមួយ ដែលមានអាហារពិសេស គឺទាខ្វៃជាមួយបន្លែ និងទឹកជ្រលក់ ដែលជាអាហាររបស់ជនជាតិចិន។ ពួកគេបានបន្តដំណើរតាមដងវិថីដែលមានមនុស្សម្នាអ៊ូអរទស្សនាការដាក់តាំងលក់របស់របរអនុស្សាវរីយ៍គ្រប់ប្រភេទ និងម្ហូបអាហារនានា។ អស់រយៈពេលបីថ្ងៃនៅក្នុងទីក្រុងប៉េកាំង ពួកគេបានបន្តដំណើរឆ្ពោះទៅ Dezhou នៅតាមផ្លូវអ្នកទាំងពីរបានបង់ពន្ធផ្លូវគ្រប់កន្លែងដែលចេះតែកើនតំលៃឡើងផងសំណាងល្អដោយប្រេងឥន្ធនៈនៅតំបន់នោះមានតំលៃថោកសមរម្យ។ ពួកគេបានឈប់សំរាកដើម្បីប្តូរគ្រឿងបន្លាស់រថយន្តដូចជាតំរងខ្យល់ និងប្រេងឥន្ធនៈ ប៉ុន្តែមិនអាចប្តូរបាន ដោយសារសំរាប់រថយន្តម៉ាកតូយូតា Toyota RAV4 នៅក្នុងប្រទេសនេះពិបាកក្នុងការរកគ្រឿងបន្លាស់ដោយគេប្រទះឃើញរថយន្តម៉ាកនេះដោយកំរ។ បន្ទាប់ពីបើកបរអស់ពេលកន្លះថ្ងៃពួកគេបានមកដល់ Dezhou នាពេលល្ងាច។











(សូមរង់ចាំអានបន្តនៅលេខក្រោយទៀត)



**ហាងខ្មែរជួសជុលរថយន្ត**

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe's Auto Service

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

FREE Shipping with Your online Order

# Fantasy Printing Co., LLC.

1243 Vine Street (13th & Vine St) - Philadelphia, PA 19107
**Tel. 215-569-3744 • Fax. 215-569-3788**
email: Fantasyprinting@comcast.net
**Open Mon.-Fri. 10-6 • Sat. & Sun by Appt.**

View sample and order online at
www.FantasyPrintingLLC.com

**Print, Design & Typeset in English, Cambodian, Chinese, Vietnamese, Korean & Japanese**

- Business Cards
- Restaurant Menu
- Wedding Invitations
- Envelopes / Tickets
- Brochures / Flyers / Envelopes
- Calendars
- Invoices / Gift Certificates
- Banners / Posters
- Signage

បោះពុម្ព-គ្រោងគំរូ-និងផ្តិតអក្សរភាសាអង់គ្លេស ខ្មែរ ចិន វៀតណាម កូរ៉េ និងជប៉ុន

- ប័ណ្ណអស័យដ្ឋាន
- តារាងម្ហូបភោជនីយដ្ឋាន
- ប័ណ្ណអញ្ជើញមង្គលការ
- ស្រោមសំបុត្រ/ប័ណ្ណលក់សំបុត្រ
- លិខិតបត់ជាសៀវភៅ/ខិតប័ណ្ណលាត
- ប្រក្រតិទិន
- ប័ណ្ណទាប្រាក់គណនេយ្យ/ប័ណ្ណឱ្យរង្វាន់
- ផ្ទាំងបដារ/ ផ្ទាំងរូបខ្នាតធំ
- ផ្លាយដាក់មុខហាង

"គុណភាពខ្ពស់តម្លៃសមរម្យ"

**"Superior Quality at Affordable Prices"**

50% OFF
**1000 Full Color Business Cards**
only **$47.50**
reg. $95.00
(FREE SHIPPING)
on 14-16 pt coated stock with / without UV coating
expires 11/30/2010



**20% OFF WEDDING INVITATIONS**
View & order online at www.fantasyprintingLLC.com
expires 11/30/2010

**5000 Full Color Post Cards**
(4x6, 2 side Full Color)
only **$250**
(FREE SHIPPING)
expires 11/30/2010

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

***(ក) កុងស្សនិសបរិសុទ្ធ រ័ត្តមានជាអនន្ត :***

ពេលដែលមនុស្សស្លាប់ទៅ រូបកាយ ពិភពផ្លូវចិត្ត របស់មនុស្ស (លំហូរគំនិត ប្រតិកម្ម អាត្មា។ល។) ក៏រលាយបាត់ទៅ ពីព្រោះវាជាផ្នែកនៃចរិក "ដែលមានទំនាក់ទំនង" ប៉ុន្តែ កុងស្សនិសបរិសុទ្ធ ឬជីវិតដែលមានចរិកជាដាច់ខាត និងជាអនន្ត នៅតែបន្ត អត្ថិភាព ប្រៀបដូច $H_2O$ ដែលខ្ញុំបានរៀបរាប់ពីមុនមកស្រាប់។ ជីវិតបន្តទៅតាមរូបភាពបែកខ្ញែក ដូចជា ធាតុទាំង៥ ទឹកដី ភ្លើង ខ្យល់ លំហរ និងថាមពលនានា (ដែលមានក្នុងរូបកាយមនុស្ស) ក៏បែកធ្លាយជ្រាបចូលទៅក្នុងធម្មជាតិ ហើយមានអត្ថិភាពជាបន្ត។ សំនួរសួរថា តើមនុស្សអាចកើតឡើងវិញឬទេ? តើអ្វីដែលនាំឱ្យមានកំណើតជាមនុស្សមកវិញ?

ឯកសារក្នុងព្រះពុទ្ធសាសនា ក៏ដូចជាព្រហ្មសាសនា គេបានបញ្ជាក់ថា **កម្ម ឬអំពើនៃមនុស្សម្នាក់ៗ** វាជាគ្រាប់ពូជ វាកម្លាំងជំរុញឱ្យមនុស្សយើងត្រឡប់មកកើតជាមនុស្ស ឬជាអ្វីផ្សេងទៀត (ជាសត្វក៏អាចមាន)។

**តើកម្មជាអ្វី?** ដូចដែលខ្ញុំបានពិពណ៌នាក្នុងវត្ថុកុងស្សនិសនៅពេលដឹងខ្លួនស្រាប់។ បាតុភូតទទួលឥទ្ធិពលពីខាងក្នុងម៉េម័រីនេះ ក្នុងភាសាសាសនា គេហៅថា **<u>កម្ម</u>** Karma គឺជាគំនរនៃអំពើ (ទាំងល្អ ទាំងអាក្រក់) ប្រព័ន្ធ និន្នាការ ការចងចាំ ការពិសោធន៍ពីអតីតកាល ដែលមនុស្សយើងម្នាក់ៗឆ្លងកាត់ (ក្នុងជាតិនេះ ឬជាច្រើនជាតិកន្លងមក)។ ទ្រឹស្តីសាសនាបាបញ្ជាក់ថែមទៀតថា កម្មនេះ គេប្រៀបដូចជាគ្រាប់ពូជដែលដេកសំងំក្នុងមនុស្សយើងម្នាក់ៗ វារង់ចាំតែពេលវេលានឹងផុះចេញជាផ្លែផ្កាប៉ុណ្ណោះ ។ មើលចុះគ្រាប់ពូជដើមពោធិ៍ វាមានទំហំប៉ុនចុងចង្កឹះ លុះដល់វាធ្លាក់ដល់ដីលក្ខខណ្ឌជុំវិញអំណោយផល វាបានក្លាយទៅជាដើមពោធិ៍ដ៏ធំស្កឹមស្កៃ (នេះជាច្បាប់ធម្មជាតិ បាតុភូតនេះមានពិតជាក់ស្តែង)។ កម្មខ្លះចេញរូបរាងនៅពេលបច្ចុប្បន្ន ខ្លះទៀតនៅរង់ចាំឱកាសនឹងបញ្ចេញនូវសកម្មភាព បើបរិដ្ឋានអំណោយឱ្យ ឬពេលវេលាទុំជោ (External stimulus)។ កម្មនេះ អន្ទោលតាមប្រាណមនុស្សម្នាក់ៗ ប្រៀបដូចស្រមោល និងរូបកាយនរណា ប្រព្រឹត្តអ្នកនោះនឹងទទួលចៀសពុំរួចឡើយ Human destiny ។

វត្ថុ សំភារៈ និងបាតុភូតទាំងអស់ ដូចជា មនុស្ស សត្វ រុក្ខជាតិ សីលា ឧស្ម័ន ផ្លាស់ប្តូររូបភាពពីមួយទៅមួយ ធ្វើចលនាគ្រាប់បែបយ៉ាង អាស្រ័យដោយមានថាមពលធម្មជាតិ។ ឧទាហរណ៍ ពន្លឺព្រះអាទិត្យដែលជាថាមពលសកលចែងចាំមកលើផែនដី រុក្ខជាតិ សត្វ បណ្តាលឱ្យរីកធំធាត់។ មនុស្សត្រូវហូបចំណីបន្លែ ត្រី សាច់ (ថាមពល) បញ្ចូលទៅក្នុងខ្លួនសំរាប់មានកម្លាំងធ្វើការសព្វយ៉ាង ប្រៀបដូចជារថយន្តត្រូវការប្រេងសាំង ដើម្បីអាចចលនាទៅមុខបាន។ ដូច្នេះ នៅពីក្រៅបាតុភូតផ្លាស់ប្តូររូបភាពប្រភេទពីមួយទៅមួយអាស្រ័យដោយកម្លាំងថាមពលនេះ។

មើលចុះ លំហូរគំនិត ប្រតិកម្ម ការរំជើបរំជួលចិត្ត ទំនោរ ម៉េម័រី ទាំងអស់នេះ សុទ្ធតែជារូបភាពនៃថាមពលទាំងអស់។ គំនិតវាជារូបភាពនៃការប្រើប្រាស់ថាមពលក្នុងរូបកាយ បើរូបកាយហេវហត់ យើងគិតអ្វីលែងបានទៀត។ កំហឹងបើវាសំដែងចេញមកក្រៅ វាអមដោយ ចំហាយកំដៅភាយៗ ចលនាញាប់ញ័រខ្លួនប្រាណ (នេះជាការកំរើកនៃថាមពល)។ ម៉េម័រីដែលដក់ជាប់ក្នុងខ្លួនមនុស្ស **ជារូបភាពថាមពលបង្កក** (ឬកម្លាំងកម្ម) ម វារង់ចាំពេលវេលាបញ្ចេញផ្លែផ្កា។ ពេលមនុស្សស្លាប់ថាមពលបង្កកនេះ ពុំបាត់ទៅណាទេ **វានឹងបន្តដំណើរនៅលើវិថីនៃជីវិតថ្មីមួយទៀត** ។ ធម្មជាតិគេមាន ច្បាប់កំណត់ ច្បាប់ឆក់ទាញតាមឋានានុក្រម Law of attraction ។ ថាមពលបង្កកនីមួយៗ មានគុណភាព មានអត្តចរិកដោយឡែកៗ (អាក្រក់ ល្អ ខ្ពស់ទាប មានកុសលអកុសល មានបុណ្យ មានបាប)។ ធម្មជាតិកណត់វិថីឱ្យថាមពលបង្កកនីមួយៗ ឆក់ទាញយោងទៅកំណើតថ្មី តាមគុណភាពរៀងៗខ្លួន មានន័យថា បើថាមពលបង្កកជោតជាំដោយកម្មក្រាស់ ភាពខ្មៅងងឹត មានបាបច្រើន នោះវានឹងឆក់ទាញទៅកាន់ដៃគូរបស់គេ ពោលគឺទីថោកទាប ទីអពមង្គល។ បើអកុសលនឹងញាំងឱ្យកើតនៅទីខ្ពង់ខ្ពស់ ទីសុខសាន្ត ទីសប្បាយរីករាយ។ ក្នុងធម្មជាតិយើងពិនិត្យឃើញថា បើអ្នកយកគ្រាប់ស្វាយពុំសែនទៅបណ្តុះដាំ វានឹងកើតបានជាដើម មែក ស្លឹក ផ្លែស្វាយពុំសែនពុំខានឡើយ នេះជាដំណើរកំណត់ញែកបំបែករបស់ធម្មជាតិ។

លុះរូបកាយថ្មីចាប់បដិសន្ធិហើយ គ្រាប់ពូជកម្ម (ថាមពលបង្កក) គេរង់ចាំឱកាសបញ្ចេញផ្លែផ្កាមកក្រៅ ជានិន្នាការ ជាចំណង់ពីក្នុងមក (ដែលយើងមនុស្សធម្មតា ពុំអាចយល់រកមូលហេតុដើមឃើញ។ យើងអាចសង្កេតឃើញឧទាហរណ៍ខ្លះៗ ក្នុងជីវិតមនុស្សរស់នៅ ខ្ញុំសូមលើកបញ្ជាក់ដូចតទៅ :

ចៅស្រីរបស់ខ្ញុំអាយុទើបតែបាន២ឆ្នាំ ទើបតែចេះដើរ រាំបង្វិលខ្លួនយ៉ាងប៉ិនប្រសប់។ ពេលខ្ញុំស្តីបន្ទោស វា១ខ្ចប់មុខពួនយំម្នាក់ឯងដូចមនុស្សចាស់។ ប៉ុន្តែលុះចំរើនធំបន្តិចមក វាភ្លេចអស់ទំនោរចាស់ពីអតីតជាតិ ប្រហែលដោយសារម៉េម័រីថ្មីចាប់ផ្តើមមានឥទ្ធិពលគ្របដណ្តប់ ។

នៅសហរដ្ឋអាមេរិក មានក្មេងប្រុសម្នាក់ កើតមកដឹងជាតិថាខ្លួនជាអតីតអ្នកបើកយន្តហោះចម្បាំងនាសង្គ្រាមលោក វាបានស្លាប់ដោយយន្តហោះត្រូវគេបាញ់ធ្លាក់។ លុះធំច្រេនិយាយ វារាយរ៉ាប់ប្រាប់ម្តាយឪពុកវាយ៉ាងលំអិត។ វាចូលចិត្តលេងល្បែងនានាទាក់ទងនឹងយន្តហោះ។ ពេលមួយនោះ ម្តាយឪពុកនាំវាទៅមើលយន្តហោះពិតប្រាកដ វាហៅឈ្មោះបន្ទាស់យន្តហោះយ៉ាងច្បាស់លាស់។ (សូមទស្សនា Internet you tube-Reincarnation, past life evidence (1/2) ) ។ មានរឿងដឹងកំណើតពីជាតិមុនជាច្រើន ក្នុងអិនទឺណែត ពាក្យគន្លឹះ incarnation you tube ។ ឥឡូវនេះមនុស្សមួយចំនួនកំពុងស្រាវជ្រាវ បាតុភូត "មនុស្សស្លាប់ហើយរស់ឡើងវិញដោយអច្ឆរយៈ" Near Death Experience គេចងក្រងជាសៀវភៅប្រវត្តិជាក់ស្តែង រាប់ពាន់ ម៉ឺនទំព័រ

**(សូមរង់ចាំអានលេខក្រោយបន្តទៀត)**






*(Continued from page 01 )*

## Pipe Bomb scared in Lynn....



The second explosion happened on October 13 where a Saturn made car parked in front of a 3 décor apartment of 3 Essex Street found exploded at about 10:20 pm. The woman who lives on the first floor said her husband is the owner of 3 Essex property. She did not want to be identify, but did confirmed that there was an explosive device blew out the car in front of her apartment. According to Lynn Daily Item, the car belong to the family who live on the 3rd floor of 3 Essex street and that Lynn Fire Dept. Arson investigator, Dave Legere believed the couple in this apartment were "possible target".

Ms. Dany Ouk, one of the family business owners on Essex Street reported she learned of the bomb incident from reading the Lynn Daily Item and watching Fox News from 2 weeks ago. She also reported her Cambodian customers did not seem to be aware of the bomb incidents.

The third bomb incidents generated panic and nervousness for the neighbors and homeowner of 80 Collins Street who discovered the pipe bomb attached to his propane gas grill on October 16. This was when the neighborhood was being evacuated. The fourth scar happened on October 18 at Red Rock Park when passersby spotted a knapsack that appeared to contain an explosive device. The bomb-disarming experts were again being called. According to the Lynn Daily Item, police found a "bottle of vodka and orange juice mixer" inside the backpack that said to belong to an intoxicated man.

**Ms. Por,** a mother of 4 boys said, "Cambodian parents should pay attention to this kind of incidents and the areas where it happened in their community, so that they can warn their children to keep out of harms way."



According to The Daily Item reporter, David Liscio, "a task force comprised of Lynn and Swampscott police and fire investigators, state troopers and federal agents from the FBI and the Bureau of Alcohol, Tobacco, Firearms and Explosives (ATF) have narrowed the search to a handful suspects." Police Chief Kevin Coppinger released a statement on October 19, per Liscio's report stated, "There are a number of persons of interest who we have been talking to. The evidence collected is being analyzed at the State Police crime lab." He also noted that "detectives are awaiting the results."


APARTMENT FOR SALE



4 Apt Units on 3rd & Grant Ave.
Northeast Phila, PA
Each/1 Bed, 1 Bath, Living room & Kitchen. Currently occupied. Generate Immediate Income.
**Asking Price $230.000.**
Contact: 267-242-5428


## តមកទំព័រទី ០១ ទស្សនកិច្ចរបស់អគ្គលេខាធិការនៃអង្គការ...

បានហើយ បើចង់បន្តទៅទៀត សូមប្រគល់រឿងនេះមកតុលាការខ្មែរទៅវិញ ។

*ចំពោះដំណើរការការិយាល័យនៃ អ.ស.ប នៅកម្ពុជាសម្រាប់សិទ្ធិមនុស្ស លោក ខៀវ កាញារីទ្ធ បាននាំពាក្យរបស់ជំនួបកំពូលនោះថា កម្ពុជាសម្រេចថាការិយាល័យត្រូវតែបិទយ៉ាងយូរណាស់នៅឆ្នាំ ២០១១ ចំណែកឯកនាយកនៃការិយាល័យនោះ គឺលោក គ្រីស្តហ្វ ប៉េស៊ូ ត្រូវតែដកចេញភ្លាម ពីព្រោះមន្ត្រី អ.ស.ប នោះមិនដែលបានមកធ្វើការពិគ្រោះជាមួយនឹងរដ្ឋាភិបាលទេ កន្លងមកច្រើននាំពាក្យរបស់គណបក្សប្រឆាំង ។

*ចំពោះតួនាទីនៃ អ.ស.ប ក្នុងជម្លោះខ្មែរ-ថៃ នៅ តំបន់ព្រះវិហារ លោក ហ៊ុន សែន សុំឱ្យ អ.ស.ប ជួយណែនាំឱ្យថៃដកទ័ពថយទៅចំណុចដើមមុនពេលកើតទំនាស់ ម្យ៉ាងទៀត អ.ស.ប អាចធ្វើអន្តរាគមន៍ប្រសិនបើមានការផ្ទុះអាវុធពីកងទ័ពក្នុងទ្រង់ទ្រាយធំ...។ល។

គួររំលឹកថា នៅពេលទស្សនកិច្ចរបស់លោក បាន គីមូន នោះមានបាតុករមួយចំនួន បានប៉ុនប៉ងធ្វើញាត្តិជូនលោកអគ្គលេខាធិការនៃ អ.ស.ប សុំឱ្យជួយពួកគេដើម្បីលក់ដីធ្លីដែលរដ្ឋាភិបាល បានរឹងអូសនោះយកមកវិញ ក៏ប៉ុន្តែត្រូវបានក្រុមប៉ូលិសបង្ក្រាបបណ្តាលឱ្យមានរបួស និងចាប់ខ្លួនបាតុករខ្លះ ។ មន្ត្រីនៃ អ.ស.ប បាននិយាយថា លិខិតដែលជាញាត្តិជូនលោក បាន គីមូន បានទទួលហើយ និងបញ្ជូនទៅលោកអគ្គលេខាធិការរួចហើយ រីឯអ្នកត្រូវគេចាប់ខ្លួននោះក៏ត្រូវបានធ្វើអន្តរាគមន៍ឱ្យចេញពីការឃុំឃាំងរួចហើយដែរ។ មន្ត្រីសិទ្ធិមនុស្សនៃ អ.ស.ប និងអង្គការក្រៅរដ្ឋាភិបាលបានថ្លែងថា "ទង្វើចំពោះបាតុករដែលសំដែងការមិនសប្បាយចិត្ត ដោយសន្តិភាពបានត្រូវទទួលការបង្ក្រាបរបៀបនេះ គឺជាអំពើរំលោភសិទ្ធិមនុស្សរបស់ក្រុមអាជ្ញាធរ ៕

## តមកទំព័រទី ០១ លោកស្រីរដ្ឋលេខាធិការក្រសួងបរទេស...

ធនធានមនុស្សសម្រាប់បំរើការក្នុងការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា"។

ទាក់ទងទៅនឹងការចង់បិទការិយាល័យសិទ្ធិមនុស្សរបស់ អ.ស.ប នៅកម្ពុជា លោកស្រី ហ៊ីឡារី បាននិយាយថា ការិយាល័យនេះ មានសារៈសំខាន់ណាស់នឹងដំណើរការជាបន្តទៅទៀត ដោយមានសហការណ៍ជារដ្ឋាភិបាលកម្ពុជា។ ចំពោះរឿងបំណុលដែលប្រទេសកម្ពុជា ក្នុងរបបសាធារណរដ្ឋខ្មែរ បានជំពាក់សហរដ្ឋអាមេរិកនោះ លោកស្រីនឹងបញ្ជូននូវអ្នកជំនាញការអាមេរិកាំង មកជជែកគ្នាជាមួយនឹងកម្ពុជា មុននឹងសម្រេចថា ត្រូវលុបចោលទាំងស្រុង ឬក៏ត្រូវបង្វែជាជំនួយអភិវឌ្ឍន៍កម្ពុជាទៅវិញ ។ រីឯបញ្ហាតុលាការខ្មែរក្រហម លោកស្រី ហ៊ីឡារី គ្លីនតុន បន្ថែមថា លោកស្រីនឹងស្នើឱ្យសហរដ្ឋអាមេរិក ផ្តល់ជំនួយបន្ថែមដល់តុលាការខ្មែរក្រហម ឱ្យអាចដំណើរការកាត់ទោសក្នុងសំណុំរឿង០០២ឱ្យបាននៅឆ្នាំ ២០១១នេះ ។

លោកស្រី ហ៊ីលឡារី បានថ្លែងទៅចំពោះសមាជិកសភានៃគណបក្សប្រឆាំង ដែលមាគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ថា លោកស្រីនឹងប្រឹងប្រែងក្នុងការធ្វើអន្តរាគមន៍ឱ្យលោក សម រង្ស៊ី អាចប្រឡប់មកធ្វើការនៅកម្ពុជាវិញបាន ពីព្រោះកម្ពុជាត្រូវការអ្នកដឹកនាំនៃគណបក្សប្រឆាំង។

រដ្ឋលេខាធិការក្រសួងការបរទេសអាមេរិកាំង បានបញ្ចប់ដំណើរទស្សនកិច្ចនៅកម្ពុជា និយាយថា "នឹងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីធ្វើកិច្ចការជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយសង្ឃឹមថា ស.រ.អា នឹងក្លាយជាដៃគូ និងជាមិត្តភក្តិដ៏ល្អជាមួយកម្ពុជា៕


Cargo *plus* East LLC.

លោកអ្នកចង់ផ្ញើអីវ៉ាន់ទៅភ្នំពេញ

យើងធានាថា ទំនិញលោកអ្នក នឹងផ្ញើទៅដល់ទីដៅ១០០% យើងយកទំនិញដោយផ្ទាល់ដៃទៅដល់មាត់ទ្វារផ្ទះ នៅគ្រប់កន្លែងនៃភ្នំពេញ
យើងមានបទបញ្ជាថា "គ្មានយកកំរៃបន្ថែមណាផ្សេង"ទៀតទេ
ប្រអប់ផ្ញើរបស់លោកអ្នកនឹងទៅដល់កន្លែងក្នុងកំណត់ ៥៥ថ្ងៃ
យើងបញ្ជូនទំនិញចេញទៅភ្នំពេញរៀងរាល់សប្តាហ៍

តម្លៃ 175 $

តាមប្រអប់ទំហំ ***21"x21"x33"*** គ្មានកំណត់ទម្ងន់

For more details, call Toll Free No: 1877-463-6217
OR KENT (267) 240-9532
Email:kkent747@yahoo.com



IN WICHTA FALLS TEXAS

**មានហាង LIQUOR នៅរដ្ឋ TEXAS ត្រូវការលក់ទាំងអគារទាំងដីរួមទាំងកន្លែងលាងឡានមួយទៀតផង ក្នុងតម្លៃ $690.000 (អាចនិយាយតថ្លៃគ្នាបាន)**

Excellent location, including land.
Liquor business (1,500 square feet), and new car wash.
Big Corner lot, good visibility, additional building can be added.
Drive through, short hour Check cashing/lottery/western union
Take home $14,000 per month income
Asking $690,000+inventory (negotiable)

Please Call Rick : 940-337-7633 (Cell), 940-687-9988 (Store)



ផ្ទះ Duplex តម្លៃ $80.000

នៅជ្រុងផ្លូវ 12Th st. និង Ruscomb st.
North Philadelphia
ផ្ទះធ្វើរួចហើយ, បង្អួចថ្មី,
ចង្ក្រានបាយ និងដំបូល
រៀបជាបន្ទប់ អាចនៅបានបីគ្រួសារ
ឥឡូវនេះមានពីរគ្រួសាររស់នៅ,
ដែលបង្កើតប្រាក់ចំណូលបានភ្លាម



ទូរស័ព្ទ : ពៅ ឆាយ 267-258-6841



AUTO GARAGE FOR SALE

HASS'S AUTO ជួសជុលតួឡានដែលបុកគ្នាម្ចាស់ហាងចូលនិវត្តន៍
-ហាងមានដំណើរការ១៧ឆ្នាំមកហើយ -ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន -ទិញដីជាមួយនឹងផ្ទះក៏បាន
-ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់
សូមទូរស័ព្ទរកឈ្មោះ "នីក"

17 years well established business.




Please Call Nick : 267-242-7938 For Showing



# ការិយាល័យច្បាប់របស់មេធាវី អេមេត ម៉ាឌិន

LAW OFFICES OF R. EMMETT MADDEN, ESQUIRE



## ការពារករណីឧក្រិដ្ឋ

- បញ្ហាធ្វើតាក់
- បញ្ហាជាមួយមន្ត្រីពន្ធដារ
- បើកបរនៅពេលស្រវឹងស្រា ឬគ្រឿងញៀន
- រំលោភរូបរាងកាយ
- ចាប់ខ្លួនដោយលក់ ឬប្រើគ្រឿងញៀន
- ក្លែងបន្លំធានារ៉ាប់រង
- ការដកហូតអាជ្ញាប័ណ្ណ
- ករណីអន្តោប្រវេសន៍

## របួសលើរាងកាយ

- គ្រោះថ្នាក់រថយន្ត
- ព្យាបាលជម្ងឺមិនត្រឹមត្រូវ
- រអិលដួល
- របួសដោយឆ្កែខាំ
- គ្រោះថ្នាក់ឡានធំ
- គ្រោះថ្នាក់កង់ម៉ូតូ
- គ្រោះថ្នាក់ផ្នែកខួរក្បាល

ពួកយើងមានបុគ្គលិកនិយាយភាសាខ្មែរ

**CALL 215-884-9300**

www.thephillylawers.com

# SAIGON PLAZA



ជាហាងថ្មីស្រឡាង ស្ថិតនៅញូជើស៊ីខាងត្បូង-យើងមានរបស់គ្រប់យ៉ាងដែលលោកអ្នកត្រូវការ នៅមិនឆ្ងាយពីផ្ទះ

新城超級市場

## SUNSENG SUPERMARKET

5201 Kaighns Ave (Route 38 W ) Pennsauken, NJ 08109

Tel : (856) 663-2238

- បន្លែបង្កាស្រស់ៗមកពីចំការ
- គ្រឿងសមុទ្រ -ត្រីរស់គ្រប់យ៉ាងដែលលោកអ្នកចូលចិត្ត
- សាច់ : មានសាច់គ្រប់មុខ សាច់ជ្រូក-មាន់-គោ-ចៀម... ។ល ។





- នៅបរិវេណប្លាហ្សា មានពាណិជ្ជកម្មផ្សេងៗទៀត ដូចជា : កាហ្វេ ទូឡាន -ហ្វើ៣៨- ABC ប្តូរលុយ -លក់សំបុត្រយន្តហោះ មានហាងកាត់ និងអ៊ុតសក់ -JB ក្រុមហ៊ុនអាស៊ាន -ក្រុមហ៊ុនធ្វើតាក់ពន្ធដារ
- បើកទ្វារមួយអាទិត្យ : ៧ថ្ងៃ ពីម៉ោង 8:00 AM ដល់ 9:00 PM
- បុគ្គលិកនៅបំរើយ៉ាងរាក់ទាក់ ដើម្បីបំពេញបំណងលោកអ្នក
- យើងទទួល Credit Card -Food Stamp-EBT- Family Card



នៅមានបន្ទប់
សំរាប់ធ្វើការិយាល័យ
សំរាប់ជួល


HONG KONG
Super Market
FAMER'S BEST
ON SALE PERIOD 11/05/10-11/11/10
HONG KONG SUPERMARKET (PA) WEEKLY PROMOTION ITEMS
3LB for $1.00
3LB for $1.00
3LB for $1.00
$0.49 per LB
3LB for $1.00
3LB for $1.00
4 for $1.00
7 for $1.00
$0.79 per LB
$7.99 per BOX
$0.69 per LB
$2.19 per LB
$1.89 per LB
FROZEN CRAB MEAT
THIT CUA
$6.99 per Box
$2.69 per bag
2LB for $9.99
$2.99 per LB
$4.99 per LB
$5.99 per LB
$2.49 per Bag
$1.49 per BLT
$2.49 per BLT
$2.99 per BLT
$1.99 per Can
$3.99 per Box
Cafe Du Monde
$3.49 per Can
Mushroom Seasoning
$6.99 per Bag
571 ADAMS AVE.PHILADELPHIA,
PA 19120 Tel : 215-7281300 Fax : 215-728-1600
ចំណាយ $140 ដុល្លារ ទទួលបានអង្ករស្រូវស 25 ផោន
ចំណាយ $100 ដុល្លារ ទទួលបានទូរភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់ ( តម្លៃ 8.99 )
ចំណាយ $25 ដុល្លារ ទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។
OPEN
7DAY
8:00-9:00

ឥតយកថ្លៃ លើ វីតាមីន
ឥតយកថ្លៃ លើ ថ្នាំចាក់ ឬលេបបង្កាជម្ងឺ
ឥតយកថ្លៃលើ យកវេជ្ជបញ្ជាទៅទិញថ្នាំ និងបញ្ជូនថ្នាំមកវិញដល់ផ្ទះ

Rx EZ PHARMACY

INTRODUCING THE MOST COST EFFECTIVE PLAN FOR SELECTED GENERIC DRUGS

$3.99 ថ្នាំសម្រាប់ប្រើ30ថ្ងៃ

$12.99 ថ្នាំសម្រាប់ប្រើ90ថ្ងៃ

215-728-6300

Bela M. Patel
Pharmacist

Hours: M-F 9-7, Sat 10-3, Sun Closed
1701 Cottman Ave. Philadelphia, PA 19111

តមកទំព័រទី ០៥

## កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយប្រធានសមាគម...

សិរិទ្ធ ប៉ែន : បាទខ្ញុំសូមជម្រាបថា មិនថាអតីតជំនាន់ៗណាទេ ឱ្យតែជាអតីតយុទ្ធជន គឺយើងទទួលយកទាំងអស់ និងទី២ គឺយើងចង់រៀបចំ Next goneration មានការធ្វើជាមួយអតីតយុទ្ធជន ហើយក៏ឱ្យពួកគាត់បានរៀនសូត្រ ដូចជាបញ្ជូនទៅរៀនផ្នែកកងទ័ពរបស់សហរដ្ឋអាមេរិក ។

**ស្តាប់ការបរិយាយរបស់លោក ថាច់ ម៉ារិន វិញម្តង**

"ខ្មែរប៉ុស្តិ៍"បានជួបសម្ភាសន៍តាមទូរស័ព្ទជាមួយលោក ថាច់ ម៉ារិន ដែលលោកមានឋានន្តរស័ក្តិជាវរៈសេនីយ៍ឯក កាលពីថ្ងៃទី៣១ ខែតុលា កន្លងមកនេះជុំវិញរឿងក្រុមអតីតយុទ្ធជន ដែលត្រូវបានបំបែកជាពីរក្រុមនេះ ។ លោក ម៉ារិន បានថ្លែងថា "ការបង្កើតសមាគមអតីតយុទ្ធជនរបស់លោក សិរិទ្ធ ប៉ែន គឺលោកគ្មានយល់ជំទាស់អ្វីឡើយ.ព្រោះនោះ ជាសិទ្ធិសេរីភាពនៃបុគ្គលម្នាក់ៗក្នុងការសម្រេចធ្វើអ្វីមួយ" ។ ប៉ុន្តែលោក ម៉ារិន បានសង្កត់ធ្ងន់ថា "ចំពោះការធ្វើអ្វីមួយដោយខុសច្បាប់ គឺអាចប្រឈមមុខជាមួយនឹងបញ្ហាផ្លូវច្បាប់បាន" ។ ការនិយាយបែបនេះ ត្រូវបានគេកាត់យល់ថា ទំនងជាចង់ដាស់តឿនក្រើនរំលឹកដល់ក្រុមលោក សិរិទ្ធ ប៉ែន កុំឱ្យធ្វើនូវអ្វីដែលប្រាស់ចាកពីច្បាប់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។

ដោយឡែកក្នុងខណៈដែលលោកបារ៉ាក់ អូបាម៉ា អញ្ជើញមកកាន់ទីក្រុងហ្វីឡាដែលហ្វៀ កាលពីថ្ងៃទី១០ ខែតុលា កន្លងមកនេះ ក្រុមអតីតយុទ្ធជន USV-JSC ដែលដឹកនាំដោយ លោក ថាច់ ម៉ារិន មួយនេះក៏មានឱកាសជួបជាមួយលោក អូបាម៉ា នៅក្នុងបន្ទប់ VIP ផងដែរ ។ លោក ម៉ារិន បានប្រាប់"ខ្មែរប៉ុស្តិ៍"ថា ពួកយើងមិនដាក់ជាសំណើរឬក៏សុំក្នុងផ្នែកណាមួយដល់លោក អូបាម៉ា ក្នុងជំនួបនោះឡើយ ដោយជំនួបនោះ គឺគ្រាន់តែជាការស្វាគមន៍ដល់លោកប្រធានាធិបតីតែប៉ុណ្ណោះ ។


វរៈសេនីយ៍ឯក ថាច់ ម៉ារិន

ឆ្លើយតាមចំពោះសំណួរ"ខ្មែរប៉ុស្តិ៍"ជុំវិញការបំពាក់ស័ក្តិលោក ម៉ារិន បានបំភ្លឺថា "ចំពោះបញ្ហាស័ក្តិទាំងនោះ គឺយើងមិនចេះតែបំពាក់ឱ្យគ្នាដោយងាយៗឡើយ គឺត្រូវបានបំពាក់ដោយក្រសួងការពារជាតិអាមេរិក ។

សូមជម្រាបថា សមាជិកនៃក្រុមអតីតយុទ្ធជន USV-JSC នេះត្រូវបានគេប្រទះឃើញរាល់សមាជិកម្នាក់ៗសុទ្ធសឹងតែមានឋានន្តរស័ក្តិធំៗចាប់តាំងពីថ្នាក់វរៈសេនីយ៍ឯក, វរៈសេនីយ៍ទោ, វរៈសេនីយ៍ត្រី, អនុសេនីយ៍ឯក និងថ្នាក់អនុសេនីយ៍ទោជាដើម ។ ដោយឡែកព្រះសង្ឃពីរអង្គនាម ញឹម ណាក់ ក៏ត្រូវបានទទួលឋានន្តរស័ក្តិជាវរៈសេនីយ៍ឯក ។ ចំណែកឯកព្រះតេជគុណ អៀវ សុវណ្ណ ត្រូវបានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ឯកផងដែរ ៕




ពេទ្យថែរក្សាធ្មេញប្រចាំគ្រួសារ
FAMILY DENTAL CARE
AT
SMILE CARE CENTER
626 Snyder Avenue. Philadelphia, Pa 19148

យើងខ្ញុំអាចបកប្រែភាសាខ្មែរជូនលោកអ្នក សូមទាក់ទងជាមួយឈ្មោះ រ៉ន ហេង និងជា លែនតាវ ដើម្បីណាត់ពិនិត្យ

WE SPEAK CAMBODIAN. PLEASE CONTACT :
MALY CHHORN 215-391-4100

Children and Adults Welcome
- Exams
- Root Canals
- Extractions
- Cleanings
- Braces
- Dental Implants

We accept all types of insurance including Medicare & Medicaid
PLEASE CALL TO MAKE YOUR APPOINTMENT TODAY !
(215) 391-4100

យើងទទួលយកគ្រប់ប្រភេទ អ៊ិនស្ទួរិន ដោយរាប់ទាំងម៉េឌីឃែ និងម៉េឌីឃេដ ផង សូមទូរស័ព្ទរកយើងខ្ញុំ នៅថ្ងៃនេះ ដើម្បីណាត់ពិនិត្យនូវលេខ (215) 391-4100

# តើខ្ញុំអាចផ្ញើប្រាក់ទៅទូទាំងប្រទេសកម្ពុជា ក្នុងតម្លៃសេវាកម្មត្រឹមតែ $11.99[1]?




# បាទ!

- ផ្ញើប្រាក់ និងទទួលប្រាក់ត្រឹមតែប៉ុន្មាននាទីប៉ុណ្ណោះ[2]
- មានទីតាំងភ្នាក់ងារច្រើនជាង 190 កន្លែង[3] នៅទូទាំងប្រទេសកម្ពុជា
- ទូទាត់ជាប្រាក់ដុល្លារអាមេរិក[4]

WESTERN UNION | yes!

westernunion.com | 1-800-325-6000 | សេវាកម្មផ្ទេរប្រាក់

រក្សាសិទ្ធិគ្រប់យ៉ាងដោយ © 2010 WESTERN UNION HOLDINGS, INC. 1

1. បន្ថែមទៅលើកម្រៃឈ្នួលនៃការផ្ទេរប្រាក់ វេស្ទើន យូនៀន ក៏អាចប្រាក់ចំណូលពីការប្តូរប្រាក់ដុល្លារ ទៅជារូបិយប័ណ្ណបរទេសផងដែរ។ កម្រៃឈ្នួលផ្សព្វផ្សាយ អាចមានទៅលើការផ្ទេរប្រាក់រហូតដល់ $500 ។ កម្រៃឈ្នួលសេវាផ្ទេរប្រាក់សម្រាប់ទីតាំងភ្នាក់ងារទូទាំងប្រទេស លើកលែងតែតំបន់ Stockton, Seattle និង Boston metro ។ 2. ចំនួនប្រាក់អាចត្រូវបានពន្យារពេល ឬមិនមានសេវាកម្ម អាស្រ័យទៅលើល័ក្ខខ័ណ្ឌនៃប្រតិបត្តិការដាក់ស្នើ រួមទាំងចំនួនប្រាក់បញ្ញើប្រទេសដែលផ្ញើទៅ លទ្ធភាពរូបិយប័ណ្ណ បញ្ហានៃការត្រួតពិនិត្យ តម្រូវការអត្តសញ្ញាណកម្ម ម៉ោងនៅតាមទីតាំងភ្នាក់ងារ ភាពខុសគ្នានៃម៉ោងនៅតាមតំបន់ ឬការជ្រើសរើសជម្រើសនៃការពន្យារពេល។ ល័ក្ខខ័ណ្ឌបន្ថែមទៀតអាចត្រូវបានអនុវត្ត។ សូមមើលលើទម្រង់បញ្ញើប្រាក់ សម្រាប់ព័ត៌មានលម្អិត។ 3. បណ្តាញទិន្នន័យគិតត្រឹមថ្ងៃទី 31 ខែមីនា ឆ្នាំ 2010 ។ 4. អាស្រ័យទៅតាមទីតាំងភ្នាក់ងារដែលបានកំណត់ និងលទ្ធភាពនៃទីតាំងនៅវេលានោះ។